# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា
## ការិយាល័យទំនាក់ទំនង
**440 N. Broad Street, Suite 102 ~ Philadelphia, PA 19130-4015 ~ (215) 400-4040**


សម្រាប់ផ្សព្វផ្សាយជាបន្ទាន់

**ទាក់ទង៖ Deirdre Darragh**
**២១៥-៤០០-៥៧៨៧**

ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣

## ការផ្សព្វផ្សាយព័ត៌មាន

ការចុះឈ្មោះ និងការវាយតម្លៃ ពិសេស
សម្រាប់សិស្សានុសិស្សអន្តោប្រវេសន៍ថ្មី ចាប់ផ្តើមនៅខែសីហា

ហ្វីឡាដែលហ្វ្យ៉ា- ការិយាល័យផ្នែក កម្មវិធី និងកម្មវិធីសិក្សា ភាសាចម្រុះ របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា សូមប្រកាសថា ចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី៣០ ខែសីហា ក្រុមគ្រួសារដែលមានកូនទើបមកដល់ប្រទេសនេះថ្មីៗ អាចបំពេញការចុះឈ្មោះសិស្សថ្មី ដោយមានជំនួយផ្នែក បកប្រែភាសា និងបកប្រែឯកសារ នៅមណ្ឌលវាយតម្លៃសិស្សដែលនិយាយភាសាចម្រុះរបស់ក្រសួងអប់រំ (MAC) ដែលស្ថិតនៅអាស័យដ្ឋានលេខ 440 North Broad Street, ជាន់ទី១ បន្ទប់លេខ ១១៩៥។

នឹងមានបុគ្គលិកចាំជួយពន្យល់អំពីវិធី ចុះឈ្មោះ ពិនិត្យមើលចំណេះដឹងរបស់ក្មេងសម្រាប់ថ្នាក់ ESOL ហើយផ្តល់ជំនួយ និងព័ត៌មាន អំពីក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា។

ឆ្នាំមុន MAC បានចុះឈ្មោះ និងវាយតម្លៃ សិស្សានុសិស្សជាង៨០០នាក់ ដែលមកពីប្រទេសជាង៧០ ដែលនិយាយភាសាជាង៤០ភាសា ខុសៗគ្នា។ យើងខ្ញុំសូមស្វាគមន៍សិស្សានុសិស្សដែលនិយាយភាសា ក្រៅពីភាសាអង់គ្លេស ដែលចង់រកជំនួយក្នុងការចុះឈ្មោះ និងការវាយតម្លៃ នៅ MAC។

សូមទាក់ទងមណ្ឌលវាយតម្លៃសិស្សដែលនិយាយភាសាចម្រុះលេខ ២១៥-៤០០-៤២៤០ (រើសយកលេខ១) ដើម្បីព័ត៌មានបន្ថែម និង/ឬ ដើម្បីធ្វើការណាត់ជួប។

**អំពី៖** ជំនួយក្នុងការចុះឈ្មោះ សម្រាប់ក្រុមគ្រួសារដែលមានកូនទើបមកដល់ប្រទេសនេះក្នុងពេលថ្មីៗ

**ទីកន្លែង៖** 440 North Broad Street, ជាន់ទី១ បន្ទប់លេខ ១១៩៥

**កាលបរិច្ឆេទ៖** ពីថ្ងៃទី៥ ដល់ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៣
ពីថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ ពីម៉ោង ៨:៣០ ព្រឹក ដល់ ៦:០០ យប់